ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧ . សរណន

# សារាចរណែនាំ

## ស្តីពី

## វិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលសិលា

កន្លងមករាជរដ្ឋាភិបាលបានចេញជាបន្តបន្ទាប់ នូវអនុក្រឹត្យ លិខិតបញ្ជា ឬសារាចរណែនាំនានាមួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន ជាពិសេសពាក់ព័ន្ធនឹងសុវត្ថិភាពសាធារណៈ ការការពារអ្នកប្រើប្រាស់ និងការទប់ស្កាត់អំពើគេចពន្ធ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលសិលា ពុំទាន់ត្រូវបានដំណើរការរលូននៅឡើយ ។ ក្រៅពីប៉ះពាល់ដល់ប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ-អាករ និងបង្កឲ្យមានអំពើអយុត្តិធម៌ក្នុងការប្រកួតប្រជែងពាណិជ្ជកម្មនោះ អាជីវកម្មនេះជារឿយៗក៏បានបង្កនូវហានិភ័យដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដូចជាការបង្កនូវអគ្គិភ័យតាមទីប្រជុំជននានា និងការជ្រៀតចូលផលិតផលខុសស្តង់ដារតាមស្ថានីយ៍ចែកចាយមួយចំនួន ដែលប៉ះពាល់ដល់ផលប្រយោជន៍អ្នកប្រើប្រាស់យានយន្ត និងគ្រឿងម៉ាស៊ីនជាទូទៅផងដែរ ។

ក្នុងន័យនេះ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ការការពារសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាអនុលោមតាមការអនុវត្តល្អជាអន្តរជាតិ ពាក់ព័ន្ធនឹងការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលសិលា រាជរដ្ឋាភិបាលសម្រេចកំណត់ដូចខាងក្រោម ៖

១. ការធ្វើអាជីវកម្មចែកចាយប្រេងឥន្ធនៈមួយចំនួន រួមមាន ប្រេងសាំង ប្រេងម៉ាស៊ូត ប្រេងកាត និងប្រេងខ្មៅ ត្រូវធ្វើឡើងតែតាមបណ្តាស្ថានីយ៍ចែកចាយ ដែលមានការអនុញ្ញាតតាមបទប្បញ្ញត្តិជាធរមាន និងមានទីតាំងតាមដងផ្លូវសាធារណៈ ឬតាមទីប្រជុំជននានា លើកលែងតែអាជីវកម្មខ្នាតតូចតាមតំបន់ជនបទ ដែលពុំទាន់មានស្ថានីយ៍ចែកចាយស្របច្បាប់ ។

២. ការបង្កើត និងការធ្វើអាជីវកម្ម ស្ថានីយ៍ចែកចាយប្រេងឥន្ធនៈនិមួយៗត្រូវមានការអនុញ្ញាតជាមុនពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងត្រូវគោរពតាមស្តង់ដារសុវត្ថិភាព និងស្តង់ដារបច្ចេកទេសផ្សេងទៀត តាមបទប្បញ្ញត្តិជាធរមាន និងត្រូវស្ថិតនៅក្នុងទីតាំងដែលមិនមែនជាល់នៅដ្ឋានងាយស្រួលដល់ការធានានូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ និងការត្រួតពិនិត្យនានារបស់អាជ្ញាធរមានសមត្ថកិច្ច ។

៣. ស្ថានីយ៍ចែកចាយប្រេងឥន្ធនៈទាំងអស់ ត្រូវមានតាំងបង្ហាញនូវស្លាកសញ្ញាសម្គាល់ក្រុមហ៊ុនអាជីវកម្មប្រេងឥន្ធនៈ ដែលជាអ្នកផ្គត់ផ្គង់ស្របច្បាប់តែមួយគត់ នូវផលិតផលទាំងនេះដល់ស្ថានីយ៍របស់ខ្លួន ។ ការផ្គត់ផ្គង់ប្រេងឥន្ធនៈពីប្រភពផ្សេងទៀត ក្រៅពីក្រុមហ៊ុនផ្គត់ផ្គង់ដែលមានស្លាកសញ្ញាសម្គាល់ក្រុមហ៊ុនតាមស្ថានីយ៍ចែកចាយនីមួយៗ ត្រូវមានការអនុញ្ញាតជាមុនពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៤. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវកំណត់បន្ថែមនូវនីតិវិធីលម្អិត ពាក់ព័ន្ធនឹងការត្រួតពិនិត្យការដឹកជញ្ជូន ចរាចរ សន្និធិ និងការកាន់រក្សាផលិតផលគេលសិលា ដែលជាទំនិញកំណត់ពិសេស តាមបញ្ញត្តិនៃច្បាប់ស្តីពីគយជាធរមាន ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងអាជីវកម្មនេះ ។

៥. អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ចុះណែនាំដោយផ្ទាល់ដល់អាជីវករ និងប្រជនពាក់ព័ន្ធឲ្យបានយល់ច្បាស់នូវខ្លឹមសារសារាចរនេះ ។ អាជីវករពាក់ព័ន្ធត្រូវចាត់ចែងកែសម្រួល ឬបំពេញបន្ថែមនូវភាពមិនប្រក្រតី ឬការខ្វះខាតនានាក្នុងកិច្ចដំណើរការអាជីវកម្មផលិតផលគេលសិលារបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវចំពោះមុខច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចាត់ចែងផ្សព្វផ្សាយឲ្យបានទូលាយ និងចូលរួមសហការត្រួតពិនិត្យការអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**ចម្លងជូន៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ